# សហគមន៍ខ្មែរកម្ពុជាក្រោម

KHMER KAMPUCHEA KROM COMMUNITY
LA COMMUNAUTÉ DU KHMER KAMPUCHEA KROM


លេខ ០៥៤/១៤ ស.ខ.ក.ក.

## ញត្តិ

**គោរពជូន**
**ឯកឧត្តម ហោ ណាំហុង**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ**

**កម្មវត្ថុៈ** សំណើកោះអញ្ជើញឯកអគ្គរដ្ឋទូតសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រចាំព្រះរាជាណាចក្រកម្ពុជា ធ្វើកំណត់ការទូត

តបតាមកម្មវត្ថុខាងលើ យើងខ្ញុំសូមជំរាបជូនឯកឧត្តម មេត្តាជ្រាបថា កាលពីថ្ងៃទី០៦ ខែមិថុនាឆ្នាំ២០១៤ លោក ត្រឹង ភ័ន់ ធុង បានថ្លែងប្រាប់វិទ្យុអាស៊ីសេរីផ្នែកភាសាខ្មែរថា *ជាក់ឯមិនបានកាត់ទឹកដីខ្មែរកម្ពុជាក្រោមឲ្យវៀតណាមទេ តែកម្ពុជាក្រោមជាទឹកដីរបស់វៀតណាមតាំងពីយូរយារណាស់មក ហើយក៏គ្មានបាត់បង់ទឹកដីគ្មានអ្វីជាមូលដ្ឋានទេ គ្មានអ្វីជាកង្វល់ទេ។*

ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៤ ស្ថានទូតវៀតណាមបានចេញថ្លែងការណ៍ថ្កោលទោសការធ្វើបាតុកម្មរបស់ សហព័ន្ធនិស្សិត បញ្ញវន្តកម្ពុជានៅមុខស្ថានទូតវៀតណាមនាព្រឹកថ្ងៃទី០៨កក្កដា២០១៤ ហើយបានគាំទ្រដល់ការថ្លែងរបស់អ្នកនាំពាក្យខាងលើ។

ថ្ងៃទី១០ខែកក្កដាឆ្នាំ២០១៤ អ្នកនាំពាក្យក្រសួងការបរទេសវៀតណាមបានប្រាប់អ្នកកាសែតនៅទីក្រុងហាណូយមានលក្ខណៈគាំទ្រដល់អ្នកនាំពាក្យរបស់ស្ថានទូតវៀតណាមបន្ថែមទៀត។

ថ្ងៃទី២១ខែកក្កដា ឆ្នាំ២០១៤ សិស្ស និស្សិត យុវជន យុវនារី ព្រះសង្ឃ និងប្រជាពលរដ្ឋខ្មែរជាងមួយម៉ឺននាក់ បានដាក់ញត្តិតវ៉ាឲ្យរដ្ឋាភិបាលវៀតណាម សុំទោស ក្នុងការនិយាយបំភ្លៃប្រវត្តិសាស្ត្រខ្មែរនេះ ក៏គ្មានអ្នកណាម្នាក់នៃស្ថានទូតវៀតណាមចេញមកទទួលញត្តិរបស់យើងខ្ញុំដែរ។

ជាបន្តបន្ទាប់ អ្នកនាំពាក្យរបស់ស្ថានទូតវៀតណាម ឈ្មោះត្រឹង ភ័ន ធុងនេះ នៅតែនិយាយប្រាប់បណ្តាញផ្សព្វផ្សាយក្នុងលក្ខណៈមើលងាយប្រជាពលរដ្ឋខ្មែរថា មិនខ្វល់នឹងញត្តិ មិនខ្វល់នឹងការធ្វើបាតុកម្មរបស់ប្រជាពលរដ្ឋខ្មែរទេ ថែមទាំងបានហៅក្រុមបាតុករខ្មែរថា ជាក្រុមមួយក្តាប់តូច ថែមទៀតផង។

ក្នុងការគោរពចំណងមិត្តភាពប្រទេសជិតខាងល្អរវាងកម្ពុជា-វៀតណាម យើងខ្ញុំបានតវ៉ាដោយសន្តិវិធី ដើម្បីឲ្យរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម ទទួលស្គាល់ការពិតនៃប្រវត្តិសាស្ត្រខ្មែរ តែវៀតណាមនៅតែធ្វើមិនដឹងមិនឮដដែល។


ទីស្នាក់ការផ្ទះលេខៈ ៧២ ផ្លូវលេខៈ ៤១៦A ភូមិគោកឃ្លាង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទលេខៈ (៨៥៥) ១២ ៩០៨ ៨៨២ / ៩៣ ៨៨ ៨៨ ០៦
E-mail: thachsetha13@gmail.com Website: http//khmerkromngo.org

សេចក្ដីដូចបានជំរាបជូនខាងលើ យើងខ្ញុំតំណាងបាតុករ សូមស្នើឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មេត្តាកោះអញ្ជើញឯកអគ្គរដ្ឋទូតសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំព្រះរាជាណាចក្រកម្ពុជា មកធ្វើកំណត់ការទូត ដើម្បីបញ្ឈប់ការបំភ្លៃប្រវត្តិសាស្ត្រខ្មែរពីសំណាក់រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាមតទៅទៀត និងជៀសវាងការភ័ន្តច្រឡំក្នុងការសិក្សារៀនសូត្រ និងស្រាវជ្រាវរបស់សិស្ស និស្សិតតទៅមុខ តាមការគួរ។

សូមឯកឧត្តមទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

រាជធានីភ្នំពេញ,ថ្ងៃទី១១ខែសីហា ឆ្នាំ២០១៤

តំណាងបាតុករ

| | |
|---|---|
| ១- ឯកឧត្តម ថាច់ សេដ្ឋា | ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម |
| ២- ភិក្ខុ ឡាយ ឡាត | អគ្គលេខាធិការសមាគមព្រះសង្ឃខ្មែរកម្ពុជាក្រោម |
| ៣-លោក សាន ណារិទ្ធិ ប្រធាន | iCambodia_យុវជនដើម្បីប្រជាធិបតេយ្យ |
| ៤-លោក គឹម សុវណ្ណារិទ្ធ | ប្រធាន I Love Cambodia Hot News |
| ៥-លោក សន ចាន់ដាភ័ | តំណាងយុវជនខ្មែរមហានគរ |
| ៦-លោក ទេព ណារិន | អនុប្រធានយុវជនដើម្បីសន្តិភាព |
| ៧-លោកយុន តុលា | ប្រធាន ក្លឹបសំឡេងយុវជនខ្មែរ_អន្តរជាតិ |
| ៨-លោក វិល្លៀម ហរណេស គីវណ្ណា | ប្រធានចលនាប្រជាធិបតេយ្យ ជាតិនិយម |
| ៩-លោក ជាសុទ្ធី | អនុប្រធានចលនាយុវជនស្ម័គ្រប្រជាធិបតេយ្យខ្មែរ |
| ១០-លោក ឈួន ភក្តិ | ប្រធានយុវជនឯករាជ្យ សង្គ្រោះបឋម (IVFAT) |
| ១១-លោក អន លីម៉ា | ប្រធានបណ្ដាញបម្រុងខ្មែរ ដើម្បីប្រជាធិបតេយ្យ |
| ១២-កញ្ញា សុខ សុធា | អ្នកសម្របសម្រួលសម្ព័ន្ធយុវជនខ្មែរដើម្បីប្រជាធិបតេយ្យ |

សូមភ្ជាប់ជូនឯកសារប្រវត្តិសាស្ត្រកម្ពុជាក្រោមសង្ខេប០១ច្បាប់


ក្រសួងការបរទេសខ្មែរ
ក្រសួងការបរទេសខ្មែរ
ត្រូវតែកោះហៅឯកអគ្គរដ្ឋទូតយួនធ្វើកណត់ការទូត